**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**ផ្ញើជូន**

សម្ដេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

*សម្ដេចជាទីរាប់អានដ៏ជ្រាលជ្រៅ,*

ភរិយាខ្ញុំ និងរូបខ្ញុំមានសេចក្ដីរីករាយជាអនេកប្បការដែលឯកឧត្តមត្រូវបានព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់សព្វព្រះរាជហឫទ័យប្រោសព្រះរាជទានគោរមងារជា **សម្ដេចពិជ័យសេនា ទៀ បាញ់** ។

សម្ដេចពិជ័យសេនា គឺជាឥស្សរជនមួយរូប ដែលបានរួមដំណើរជាមួយខ្ញុំ និងថ្នាក់ដឹកនាំផ្សេងទៀតរយៈពេលជិត ៤០ ឆ្នាំ មកហើយ ដោយសហការគ្នាដោះស្រាយរាល់ការងារលំបាក ពិសេសសម្ដេចគឺជាប្រតិបត្តិករដ៏មានសមត្ថភាព និងស្មោះត្រង់ក្នុងការអនុវត្តន៍នយោបាយឈ្នះ ឈ្នះ នាំមកនូវសន្តិភាពការបង្រួបបង្រួមជាតិ ការឯកភាពដឹកដី និងអភិវឌ្ឍន៍ប្រទេសជាតិរហូតដល់សព្វថ្ងៃ ។

ខ្ញុំសូមជូនពរសម្ដេចពិជ័យសេនា និងលោកជំទាវប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងសូមសម្រេចបានជោគជ័យក្នុងគ្រប់ភារកិច្ចបម្រើជាតិ និងមាតុភូមិ ។

សូមសម្ដេចពិជ័យសេនា និងលោកជំទាវទទួលនូវការរាប់អានពីខ្ញុំ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៧*

**ហ៊ុន សែន**